# លះបង់សុខតូច ដើម្បីឈោងចាប់យកសុខធំ

វិស័យពុទ្ធសាសនិកជនគឺជាអ្នកភ្ញាក់រលឹកជាប់ជានិច្ច ហើយជាអ្នកមើលឃើញសេចក្តីចំរើននិងភាពត្រឹមត្រូវជាធំ។ តាមគំរូព្រះពុទ្ធបរមគ្រូ រាប់ចាប់ពីព្រះអង្គកើតជាព្រះពោធិសាត់ រហូតជាតិចុងក្រោយជាព្រះសិទ្ធត្ថកុមារ ព្រះអង្គរមែងធ្វើការបរិច្ចាគទាន ដែលយើងជាបុថុជ្ជន ឬជាជនសាមញ្ញធម្មតាមិនអាចធ្វើបាន ។

កាលជាតិជាព្រះវេសន្តរ ព្រះអង្គបានធ្វើអនុបារមីទាន ដោយបរិច្ចាគបុត្រាបុត្រីគួរជាទីស្រឡាញ់ពេញចិត្តទៅឲ្យស្មូមជជក់។ ព្រះវេសន្តរមានសេចក្តីស្រឡាញ់ អាណិតអាសូរព្រះរាជបុត្រយ៉ាងខ្លាំង តែធ្វើម្តេចបានទៅ បើព្រះអង្គមិនធ្វើដូច្នោះ ភាពជាបរមគ្រូនៃទេវតានិងមនុស្សទាំងឡាយ ឬភាពជាព្រះសម្មាសម្ពុទ្ធៈ ដើម្បីជួយស្រោចស្រង់សត្វលោកទាំងចក្រវាឡមិនអាចប្រព្រឹត្តទៅរួចបានទេ ។

រហូតជាតិជាចុងក្រោយជាព្រះសិទ្ធត្ថកុមារ ព្រះអង្គមានភាពអាឡោះអាល័យចំពោះព្រះរាហុលកុមារដែលជាបុត្រា និងនាងពិម្ពារជាអគ្គមហេសីយ៉ាងខ្លាំង តែធ្វើម្តេចកើត បើព្រះអង្គមិនដាច់ចិត្តចេញចាកទៅសាងព្រះផ្នួសទេ ព្រះអង្គមិនអាចសំរេចជាព្រះពុទ្ធបានឡើយ។ បើមិនបានត្រាស់ជាព្រះពុទ្ធទេ ក្រុមគ្រួសារញាតិវង្ស សត្វលោកទាំងឡាយ និងកើត ចាស់ ឈឺ ស្លាប់ ដែលជាអណ្តូងត្រាំនៃទឹកភ្នែកនិងសេចក្តីទុក្ខ នៅតែមានគ្មានថ្ងៃណាស្រាកស្រាន្តឡើយ ។

ប្រការដែលព្រះវេសន្តរបរិច្ចាគបុត្រាបុត្រីជាទានបារមី ឬការដែលព្រះអង្គចេញទៅសាងព្រះផ្នួសចោលបុត្រានិងអគ្គមហេសី *មិនមែនមានន័យថាព្រះអង្គមិនស្រឡាញ់បុត្រាភរិយាក្រុមគ្រួសារនោះទេ ព្រះអង្គមានសេចក្តីស្រឡាញ់ប្រកបដោយមេត្តាករុណាជ្រាលជ្រៅ តែនេះជាកាតព្វកិច្ចរបស់ព្រះពុទ្ធទាំងឡាយ ដែលមិនដែលគិតដូចបុថុជ្ជនអ្នកគ្មានបញ្ញានោះទេ ព្រះអង្គសុកចិត្តលះបង់អ្វីៗទាំងអស់សូម្បីតែសម្បត្តិទ្រព្យ តំណែងបុណ្យសក្តិ បុត្រភរិយា*

*និងជីវិតរបស់ព្រះអង្គផ្ទាល់ក៏ដោយ ដើម្បីបានប្រយោជន៍ធំ ហើយទើបជួយស្រោចស្រង់សត្វលោកនិងព្រះញាតិវង្សជាក្រោយ ។*

ចំណែកអ្នកដែលគិតថា ព្រះពុទ្ធអង្គចេញទៅសាងព្រះផ្នួសមិនមានទឹកចិត្តស្រឡាញ់កូន ភរិយា និងក្រុមគ្រួសារនោះ គ្រាន់តែជាការវាយប្រហារដោយការយល់មិនដល់ ខ្វះសតិបញ្ញា ឬការគិតឃើញតាមបែបមនុស្សដែលប្រកបដោយ**លោភៈ ទោសៈ និងមោហៈ** ហើយបុគ្គលដែលនិយាយនោះមិនអាចលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីសេចក្តីសុខអ្នកដទៃបានឡើយ ។

វិស័យពុទ្ធសាសនិកជនពិតប្រាកដគឺដូច្នេះៈ ត្រូវតែហ៊ានធ្វើពលីកម្ម ត្រូវតែភ្ញាក់រលឹកនិងអភិវឌ្ឍន៍ខ្លួនជានិច្ច។ អភិវឌ្ឍន៍ខ្លួនពីភាពជាអ្នកសុំទានគេ ទៅជាមនុស្សដែលអាចជួយខ្លួនឯងបាន, អភិវឌ្ឍន៍ពីភាពជាអ្នកធ្វើកម្មករទៅជាថៅកែគេ, អភិវឌ្ឍន៍ពីជនអវិជ្ជាទៅជាជនអ្នកត្រាស់ដឹង និងអភិវឌ្ឍន៍ពីសាមញ្ញជនឲ្យទៅជាអរិយជនជាដើម ។